ក្រសួងសុខាភិបាល

# សេចក្តីជូនដំណឹងរបស់ក្រសួងសុខាភិបាល
## ស្តីពី
## វិធានការការពារជំងឺគ្រុនឈាម ដើម្បីទប់ស្កាត់សភាពអាចផ្ទុះឡើងនូវជំងឺគ្រុនឈាម ក្នុងឆ្នាំ២០១៩

ក្រសួងសុខាភិបាល សូមជម្រាបជូនសាធារណជន និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ទាំងអស់មេត្តាជ្រាបថា ករណីជំងឺគ្រុនឈាមនៅទូទាំងប្រទេសក្នុងដើមឆ្នាំ២០១៩នេះ មានការកើនឡើងគួរឲ្យកត់សម្គាល់ ច្រើនជាងឆ្នាំ២០១៨កន្លងទៅ បើប្រៀបធៀបទៅនឹងពេលវេលាដូចគ្នា។ កត្តាមួយក្នុងចំណោមកត្តាជាច្រើនដែលបង្កឲ្យមានជំងឺគ្រុនឈាមនោះ គឺបំរែបំរួលអាកាសធាតុ និងវត្តមានជម្រកមូសខ្លា នៅតាមផ្ទះសម្បែង ឬទីធ្លាសាធារណៈ។ តាមការវិភាគអេពីដេមីសាស្ត្រ និងការប៉ាន់ប្រមើលលើស្ថានភាពជំងឺគ្រុនឈាមរបស់អង្គការសុខភាពពិភពលោក បង្ហាញថាជំងឺគ្រុនឈាមប្រហែលជាអាចនឹងផ្ទុះឡើងនៅក្នុងឆ្នាំ២០១៩នេះ ដែលតម្រូវឲ្យប្រជាពលរដ្ឋនិងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ មានការប្រុងប្រយ័ត្នយកចិត្តទុកដាក់ចូលរួមយ៉ាងសកម្មក្នុងការអនុវត្តនីវិធានការមានដូចខាងក្រោម ដើម្បីចៀសផុតពីភាពអាចមានការផ្ទុះឡើងនូវជំងឺគ្រុនឈាម នៅក្នុងឆ្នាំនេះ និងឆ្នាំបន្តបន្ទាប់ទៀត។

ជំងឺគ្រុនឈាម ជាជំងឺអាចកើតឡើងលើមនុស្សគ្រប់វ័យ ដែលបង្កឡើងដោយមូសខ្លាញីខាំបឺតឈាមអ្នកដែលមានវីរុសគ្រុនឈាម ចម្លងពីមនុស្សម្នាក់ទៅម្នាក់ទៀត។ មូសខ្លា កកើតកូនចៅនៅក្នុងទឹកថ្លាស្អាត និងចូលចិត្តរស់នៅជិតមនុស្ស ហើយហើរក្នុងចំងាយមិនលើសពី១៥០ម៉ែត្រពីជម្រកកកើតមូស។ ជំងឺគ្រុនឈាមមានរោគសញ្ញាដូចតទៅ៖ ២ទៅ៣ថ្ងៃក្រោយពីមូសខ្លាញីខាំ អ្នកជំងឺមានក្តៅខ្លួនពី ៣៩ ទៅ ៤០ អង្សាសេ អមដោយរោគសញ្ញាផ្សេងៗទៀតដូចជា មុខក្រហម ឈឺប្រឡង់កែវភ្នែកចាក់ទៅក្រោយ ឈឺក្បាល ចង់ក្អួត ឬក្អួត ឈឺពោះ ឈឺសាច់ដុំ ឈឺសន្លាក់ដៃជើង ស្នាមអុចៗក្រហមលើស្បែក ឬមានហូរឈាមតាម ចិញ្ចាញធ្មេញ ជាដើម។

យោងតាមការស្រាវជ្រាវបាណកសាស្ត្រ របស់កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាមនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រនៃក្រសួងសុខាភិបាល រួមសហការជាមួយមន្ទីរសុខាភិបាលរាជធានី-ខេត្ត បានបញ្ជាក់ឲ្យឃើញថា មូសខ្លាចូលចិត្តពងនិងបង្កបង្កើតកូនចៅ ក្នុងសំបកកង់ឡាន និងសំបកកង់ម៉ូតូចាស់ៗ ចំនួន១១ដង ច្រើនជាងវត្ថុដក់ទឹក ឬដាក់ទឹកផ្សេងៗ។ នៅក្នុងខែមករា ឆ្នាំ២០១៩ កន្លងមកនេះ កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាមបានធ្វើការអង្កេតបាណកសាស្ត្រនៅតាមទីតាំងដែលបានជ្រើសរើសសម្រាប់ធ្វើការសិក្សា និងពិនិត្យតាមដានស្ថានភាពមូសខ្លាក្នុងរាជធានីភ្នំពេញនារដូវប្រាំងនេះ ដែលលទ្ធផលបានបង្ហាញឲ្យឃើញថា មូសស្ទើរតែទាំងអស់សុទ្ធតែជាមូសអង្កាម។



ទីស្តីការក្រសួងសុខាភិបាល វិថីលេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៥ ៤០៤

ដើម្បីការពារសុខភាពបុគ្គលឲ្យជៀសផុតពីការឆ្លងជំងឺគ្រុនឈាមដោយសារមូសខ្លាញ់ខាំ និងដើម្បីទប់ស្កាត់ករណីដែលអាចផ្ទុះឡើងនូវជំងឺគ្រុនឈាមក្នុងឆ្នាំ២០១៩នេះ ជាពិសេស ដើម្បីបង្ការការឈឺ និងស្លាប់ដោយសារជំងឺគ្រុនឈាមឲ្យមានប្រសិទ្ធភាពខ្ពស់នោះ **ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាលសូមអំពាវនាវនិងធ្វើការណែនាំដល់ប្រជាពលរដ្ឋគ្រប់រូប ត្រូវចូលរួមលុបបំបាត់ជម្រកមូសខ្លាដោយប្រកាន់ខ្ជាប់ខ្ជួននូវទម្លាប់រស់នៅជាគំរូល្អគឺ "**ខ្ញុំ និងគ្រួសារខ្ញុំ ជាគ្រួសារគំរូ ព្រោះផ្ទះខ្ញុំ និងលំនៅដ្ឋានរបស់ខ្ញុំគ្មានជង្គូវទឹក**" តាមរយៈការអនុវត្តនូវវិធានការ ដូចខាងក្រោម៖

**វិធានការទី១៖** អាណាព្យាបាល មាតាបិតា កុមារាកុមារី គ្រប់រូប ត្រូវកំចាត់ជង្គូវទឹកនៅតាមកន្លែងទឹកដក់ ឬវត្ថុសម្រាប់ដាក់ទឹក ដូចជា ពាងទឹក អាងទឹក ថូផ្កា ចានទ្រជើងតុទូ ក្រឡ ធុង ខាប់ ជាដើម ដោយមានការផ្លាស់ប្តូរទឹក និងលាងសំអាតរបស់ទាំងនោះ ជាប់ជាប្រចាំឲ្យបានយ៉ាងតិចមួយដងក្នុងមួយសប្តាហ៍ ឬត្រូវគ្របគំរបឲ្យបានជិតល្អ និងត្រូវសហការជាមួយបណ្តាញសុខាភិបាល ដើម្បីដាក់ថ្នាំអាបែត សម្លាប់ជង្គូវទឹក ឬចិញ្ចឹមកូនត្រីប្រាំពីរពណ៌នៅកន្លែងដែលអាចចិញ្ចឹមបាន។ ចំពោះសម្ភារៈដក់ទឹកផ្សេងទៀត ដែលមិនប្រើប្រាស់ទុកចោល ដូចជាសំបកកង់ឡាន ឬម៉ូតូ សំបកដបឬកំប៉ុង ត្រឡោកដូង និងវត្ថុដក់ទឹកផ្សេងទៀត ត្រូវកប់ ឬដុត ឬកំទេចចោល ឬទុកដាក់ផ្កាប់ឲ្យមានរបៀប កុំឲ្យមានទឹកដក់។

**វិធានការទី២៖** អាជីវករ និងម្ចាស់អាជីវកម្មទាំងឡាយដែលប្រកបរបរពាក់ព័ន្ធនឹងសំបកកង់ ពិសេសសំបកកង់ឡាន និងសំបកកង់ម៉ូតូទាំងអស់ *"សូមធ្វើការគ្រប់គ្រងសំបកកង់ទាំងនោះឲ្យមានសុវត្ថិភាពជៀសផុតពីការដក់ទឹក"* ដោយមិនត្រូវទុកចោលពាសវាលពាសកាល បង្កើតបានជាប្រភពកកើត និងជាជម្រកមូសខ្លាដ៏គ្រោះថ្នាក់បំផុត ដែលជាអំណោយផលដល់ការចម្លងជំងឺគ្រុនឈាម។ វិធីសាស្ត្រក្នុងការគ្រប់គ្រងសំបកកង់ដោយសុវត្ថិភាពគ្មានសត្វមូសកកើតគឺត្រូវ៖ *ដាក់តម្រួតលើគ្នា គ្របដោយបន្ទះក្តារជិត ឬស្បៃមុង ចាក់ប្រេងម៉ាស៊ីនដែលខូចឈប់ប្រើប្រាស់ចូល ឬចាក់ដីបំពេញ ជាពិសេសដាក់នៅក្រោមដំបូល* ដើម្បីការពារកុំឲ្យមានដក់ទឹក ដែលបង្កទៅជាប្រភពកកើត និងជម្រកមូសខ្លា។

**វិធានការទី៣៖** ករណីមានរោគសញ្ញាក្តៅខ្លួនខ្លាំងភ្លាមៗចៀសវាងការប្រើប្រាស់ពពួកឱសថអាស្ពីរីន ហើយត្រូវប្រញាប់នាំអ្នកជំងឺទៅរកសេវាពិនិត្យ និងព្យាបាលនៅមន្ទីរពេទ្យ ឬមណ្ឌលសុខភាពរដ្ឋ (មូលដ្ឋានសុខាភិបាលសាធារណៈ) ដែលនៅជិតលោកអ្នកបំផុត (មិនឲ្យយឺតជាង ៧២ម៉ោង បន្ទាប់ពីក្តៅខ្លួន) ហើយសូមកុំសាកល្បងព្យាបាលអ្នកជំងឺគ្រុនក្តៅខ្លាំងភ្លាមៗនេះដោយខ្លួនឯង ឬពន្យារពេលតាមដានព្យាបាលជំងឺនៅសេវាឯកជនដែលមិនមានជំនាញវិជ្ជាជីវៈផ្នែកជំងឺគ្រុនឈាមនេះឲ្យសោះ ព្រោះជំងឺគ្រុនឈាមអាចនឹងសម្លាប់អ្នកជំងឺបានគ្រប់ពេល។

បន្ថែមលើវិធានការទាំង៣ខាងលើនេះ ក្រសួងសុខាភិបាលសូមជម្រាបជូនថា យោងតាមការណែនាំរបស់អង្គការសុខភាពពិភពលោក ការបាញ់ថ្នាំមូសត្រូវធ្វើឡើងក្នុងករណីមានការរាតត្បាតជំងឺ ហើយប្រើបានតែក្នុងរយៈពេលខ្លីតែប៉ុណ្ណោះ។ ការបាញ់ថ្នាំមូសជាញឹកញាប់ ច្រើនកន្លែង និងមានរយៈពេលយូរបណ្តាលឲ្យមូសគ្រប់ប្រភេទមានភាពស៊ាំទៅនឹងថ្នាំដែលបានបាញ់ ដែលធ្វើឲ្យការឆ្លើយតបនិងអន្តរាគមន៍បន្ទាន់ នៅពេលមានហេតុការណ៍ការរាតត្បាតជំងឺដែលអាចកើតមានឡើងនាពេលខាងមុខគ្មានប្រសិទ្ធភាព។

ក្រសួងសុខាភិបាល សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនដល់ប្រជាពលរដ្ឋដែលបានយកចិត្តទុកដាក់អនុវត្តន៍តាមការណែនាំខាងលើ និងជូនដល់ថ្នាក់ដឹកនាំនិងមន្ត្រីសុខាភិបាល អាជ្ញាធរមូលដ្ឋាន ក្រសួង មន្ទីរ ឬអង្គភាពពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមអន្តរាគមន៍ និងសហការពេញលេញ ព្រមទាំងបន្តជួយឧបត្ថម្ភ គាំទ្រ និងសហការចូលរួមជាមួយកម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាមនៃក្រសួងសុខាភិបាល ក៏ដូចជាជាមួយមន្ទីរសុខាភិបាលរាជធានី-ខេត្តទាំង២៥ និងសូមអំពាវនាវឲ្យមានការចូលរួមបន្តសកម្មភាពការពារប្រសើរជាងព្យាបាល និងសហការអនុវត្តនូវវិធានការទាំង៣ខាងលើនេះ ដើម្បីរួមគ្នាទប់ស្កាត់ការអាចផ្ទុះឡើង ឬការរាតត្បាតជំងឺគ្រុនឈាមដែលអាចកើតមានឡើងក្នុងឆ្នាំ២០១៩នេះ ព្រមទាំងរួមគ្នាកាត់បន្ថយនូវអត្រាឈឺ និងស្លាប់ដោយសារជំងឺគ្រុនឈាមផងដែរ។

សូមប្រសិទ្ធពរជ័យជូនដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ឲ្យទទួលបាននូវសុខភាពល្អទាំងអស់គ្នា។

ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖
លោកវេជ្ជបណ្ឌិត លាង ឫទ្ធា ដែលមានលេខទូរស័ព្ទ ០១២ ៧១៥ ៦៦៦ អ៊ីម៉ែល
rithealeang@gmail.com

ថ្ងៃចន្ទ ១៣រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៩